**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៤

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## ជំពូកទី២

## មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ដោយឈរលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ ច្បាប់ជាតិនិងច្បាប់អន្តរជាតិ
- កសាងព្រំដែនពេញលេញ ច្បាស់លាស់ និងស្ថាពរ ជាព្រំដែនមិត្តភាព សន្តិភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ
- ចរចាជាមួយប្រទេសជិតខាង ដើម្បីធ្វើការខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងធ្វើការកំណត់ព្រំដែនសមុទ្រ
- រៀបចំបង្កើតបទដ្ឋានបច្ចេកទេស ស្ដីពីការងារវាស់វែង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការផលិតផែនទីទាំងព្រំដែនគោកនិងសមុទ្រ និងគោលការណ៍ណែនាំនានាដែលពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ផលិតផែនទីព្រំដែន បង្គោលព្រំដែន និងសញ្ញាសម្គាល់ព្រំដែនជាមួយប្រទេសជិតខាង
- ថែរក្សាការពារខ្សែបន្ទាត់ព្រំដែន បង្គោលព្រំដែន និងសញ្ញាសម្គាល់ព្រំដែននៅតាមតំបន់ឯកភាព ព្រមទាំងថែរក្សាស្ថានភាពដើមនៅក្នុងតំបន់ដែលមិនទាន់ឯកភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- ដោះស្រាយបាតុភាពនានាពាក់ព័ន្ធកិច្ចការព្រំដែនដែលកើតមានឡើងនៅតាមបណ្ដោយព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- សិក្សានិងវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់ដែលកើតចេញពីកិច្ចការព្រំដែន គម្រោងវិនិយោគ និងគម្រោងអភិវឌ្ឍន៍នានានៅតាមតំបន់ព្រំដែនពាក់ព័ន្ធនឹងកិច្ចការព្រំដែន ព្រមទាំងសហការដោះស្រាយផលប៉ះពាល់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- លើកសំណើសុំការដោះស្រាយផលប៉ះពាល់ពីការងារខណ្ឌសីមា បោះបង្គោលព្រំដែន និងអភិវឌ្ឍតំបន់ព្រំដែន ដើម្បីគោរពស្នើសុំការពិនិត្យ សម្រេចពីប្រមុខរាជរដ្ឋាភិបាល
- ដឹកនាំ សម្របសម្រួលយន្តការអន្តរក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន ក្នុងការរៀបចំតាក់តែងសេចក្ដីព្រាងសន្ធិសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការព្រំដែនជាមួយប្រទេសជិតខាង ក្រោយទទួលបានការអនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល



គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

- សិក្សា ស្រាវជ្រាវ និងចងក្រងសន្ធិសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឧត្តមានុវត្តពាក់ព័ន្ធកិច្ចការព្រំដែនគោកនិងព្រំដែនសមុទ្រ
- សិក្សា ស្រាវជ្រាវ និងវិភាគជាយុទ្ធសាស្ត្រលើកិច្ចការព្រំដែន
- កសាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ ផែនការមេ និងផែនការសកម្មភាពនានា ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់កិច្ចការពារនិងអភិវឌ្ឍន៍តំបន់ព្រំដែន
- រៀបចំ កសាង និងដឹកនាំអភិវឌ្ឍន៍តំបន់ព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- ចូលរួមត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចក្នុងក្របខ័ណ្ឌបច្ចេកទេសព្រំដែនលើគម្រោងវិនិយោគនិងគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន
- ដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ ផែនការមេ និងផែនការសកម្មភាពពាក់ព័ន្ធកិច្ចការព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- កសាងដៃគូយុទ្ធសាស្ត្រ ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍កិច្ចការព្រំដែន
- ត្រួតពិនិត្យរាល់គម្រោងនិងការសាងសង់សំណង់ ការរៀបហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការគ្រប់គ្រង ការប្រើប្រាស់ និងការអាស្រ័យផលលើដីនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែន ដើម្បីបង្ការផលប៉ះពាល់ដល់ការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនក្នុងតំបន់ដែលមិនទាន់ឯកភាព ព្រមទាំងថែរក្សាការពារខ្សែបន្ទាត់ព្រំដែន បង្គោលព្រំដែន និងសញ្ញាសម្គាល់ព្រំដែនដែលបានឯកភាព
- រៀបចំផែនការគ្រប់គ្រង ថែរក្សា និងចាត់ចែងសំណល់ដីដែលទទួលបានបន្ទាប់ពីការខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកជាមួយប្រទេសជិតខាង
- រៀបចំនិងអភិវឌ្ឍវិទ្យាស្ថានជាតិកិច្ចការព្រំដែន ដើម្បីកសាងនិងបណ្តុះបណ្តាលធនធានមនុស្សជំនាញលើច្បាប់ជាតិ ច្បាប់អន្តរជាតិ ផែនទី ឋានលេខាសាស្ត្រ ប្រើថពីវិទ្យា ភូគព្ភសាស្ត្រ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងបច្ចេកទេសផ្សេងៗទៀតពាក់ព័ន្ធកិច្ចការព្រំដែន
- សិក្សា ស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយចំណេះដឹងទូទៅពាក់ព័ន្ធព្រំដែន ជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំមជ្ឈមណ្ឌលតម្កល់និងថែទាំឯកសារ ផែនទី និងទិន្នន័យកិច្ចការព្រំដែន
- សហការជាមួយភាគីពាក់ព័ន្ធ ទាំងក្នុងវិស័យសាធារណៈនិងឯកជន ដើម្បីលើកកម្ពស់ចលនាកសាងនិងអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចតាមតំបន់ព្រំដែន
- អនុវត្តមុខងារនិងភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៣ .-**

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនមានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន

- អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន
- វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនអាចស្នើសុំបង្កើតអង្គភាពមូលដ្ឋានកិច្ចការព្រំដែនតាមការចាំបាច់ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

អគ្គនាយកដ្ឋានចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវដឹកនាំដោយអគ្គនាយក១(មួយ)រូប និងមានអគ្គនាយករងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានជាតិកិច្ចការព្រំដែន ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយព្រះរាជក្រឹត្យ និងមាននាយករងមួយចំនួនតាមការចាំបាច់ តែងតាំងដោយអនុក្រឹត្យ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋានតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យនីមួយៗចំណុះនាយកដ្ឋាន និងមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែនរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពមូលដ្ឋានកិច្ចការព្រំដែនក្រោមឱវាទរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**មាត្រា៦ .-**

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនអាចមានទីប្រឹក្សានិងជំនួយការមួយចំនួន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន និងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា៨ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការគ្រប់គ្រងនិងសម្របសម្រួលរួមលើការងាររដ្ឋបាល ភស្តុភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ទំនាក់ទំនងអន្តរជាតិ នីតិកម្ម ព័ត៌មានវិទ្យានៃគ្រប់អគ្គនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពចំណុះ ហើយមានភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវនិងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងផែនការថវិការបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន រយៈពេលខ្លី មធ្យម និងវែង ស្របតាមគោលនយោបាយនិងផែនការរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រង ទទួលខុសត្រូវ និងសម្របសម្រួលកិច្ចការរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុទូទៅ
- រៀបចំ គ្រប់គ្រងមន្ត្រីរាជការ និងអភិវឌ្ឍធនធានមនុស្ស
- គ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យ
- គ្រប់គ្រងនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈ
- គ្រប់គ្រង ថែទាំសម្ភារៈ បរិក្ខារ និងទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងនិងសម្របសម្រួលកិច្ចការពិធីការ ទំនាក់ទំនងអន្តរជាតិ និងនីតិកម្ម
- សម្របសម្រួលការអនុវត្តគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល មានជាអាទិ៍ការកែទម្រង់រដ្ឋបាលសាធារណៈនិងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងនិងចាត់ចែងកិច្ចគាំពារសង្គមសម្រាប់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា
- ដឹកនាំរៀបចំសន្និបាតប្រចាំឆ្នាំនិងពិធីបុណ្យប្រពៃណីជាតិនិងអន្តរជាតិផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- សម្របសម្រួលរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារនិងទិសដៅបន្តរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយសហការជាមួយអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងអង្គភាពចំណុះ
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**មាត្រា៩ .-**

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន៥(ប្រាំ) ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលនិងពិធីការ
- នាយកដ្ឋានហិរញ្ញវត្ថុ
- នាយកដ្ឋានធនធានមនុស្ស
- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម
- នាយកដ្ឋានព័ត៌មានវិទ្យា។

**មាត្រា១០ .-**

នាយកដ្ឋានរដ្ឋបាលនិងពិធីការ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលសកម្មភាពការងាររដ្ឋបាលរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ជាមួយអង្គភាពចំណុះ
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំ ពិនិត្យ និងកែសម្រួលលិខិតរដ្ឋបាលទូទៅ
- សម្របសម្រួលជាមួយអង្គភាពផ្ទៃក្នុង ក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន ដើម្បីរៀបចំកិច្ចប្រជុំផ្ទៃក្នុង កិច្ចប្រជុំទ្វេភាគី ឬកិច្ចប្រជុំពហុភាគី ជាមួយប្រទេសជិតខាង
- រៀបចំកំណត់ហេតុឬរបាយការណ៍គ្រប់កិច្ចប្រជុំរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជួយសម្រួលដល់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការចុះទៅបំពេញបេសកកម្មការងារលើទីតាំងជាក់ស្តែង
- រៀបចំផែនការសកម្មភាពទាក់ទងនឹងកិច្ចប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីបុណ្យផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយពិគ្រោះយោបល់ជាមួយអង្គភាពចំណុះពាក់ព័ន្ធ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារនិងទិសដៅបន្តរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយសហការជាមួយអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ចូលរួមរៀបចំនិងសម្របសម្រួលការងារពិធីការនិងសុវត្ថិភាពជូនថ្នាក់ដឹកនាំ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ របស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១១ .-**

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម៖

- ប្រមូលផ្តុំ សម្របសម្រួល បូកសរុប និងរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ប្រមូលផ្តុំ សម្របសម្រួល បូកសរុប និងលើកគម្រោងថវិកាប្រចាំឆ្នាំ
- គាំទ្រនិងសម្របសម្រួលជាមួយអង្គភាពថវិកាក្នុងការគ្រប់គ្រងថវិកា
- ទទួលខុសត្រូវលើកិច្ចការប្រតិបត្តិការចំណូល ចំណាយប្រចាំឆ្នាំ និងកិច្ចបញ្ជិការគណនេយ្យ
- រៀបចំ គ្រប់គ្រង និងអនុវត្តផែនការលទ្ធកម្ម
- គ្រប់គ្រងនិងថែទាំចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ បរិក្ខារ និងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិគ្រប់កម្រិត
- ទទួលនិងបែងចែកចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ បរិក្ខារ ប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ផ្សេងៗ ជូនដល់បណ្តាអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំចុះកិច្ចបញ្ជិការជាប្រចាំ
- សម្របសម្រួលនិងរៀបចំគម្រោងចំណាយ សាងសង់ ជួសជុល ថែទាំអគារ រដ្ឋបាល និងទ្រព្យសម្បត្តិរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការ ព្រំដែន

- គ្រប់គ្រងនិងថែទាំឧបករណ៍ សម្ភារ បរិក្ខារគ្រប់ប្រភេទ សម្រាប់បម្រើឱ្យការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងផលិតផែនទី ដោយសហការជាមួយអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន
- លើកសំណើជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យនិងផ្តល់យោបល់លើការងារដែលទាក់ទងនឹងភស្តុភារនិងហិរញ្ញវត្ថុ និងស្នើសុំមតិដឹកនាំពីរដ្ឋមន្ត្រី ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសនិងប្រចាំឆ្នាំរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-**

នាយកដ្ឋានធនធានមនុស្សមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានមនុស្ស
- គ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា
- វាយតម្លៃតម្រូវការជំនាញសម្រាប់ទ្រទ្រង់ការអភិវឌ្ឍសមត្ថភាពរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ត្រួតពិនិត្យនិងវាយតម្លៃគុណផលការងាររបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន មានជាអាទិ៍ការជ្រើសរើស ការរៀបចំបៀវត្ស ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ការប្រឡងផ្ទៃក្នុង ការផ្ទេរនិងការប្រគល់ភារកិច្ច ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការលាឈប់ ការដាក់ពិន័យ ការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលនិវត្តន៍ ការផ្តល់រង្វាន់ ការផ្តល់គ្រឿងឥស្សរិយយស កម្មវិធីប្រឡងប្រណាំង
- ចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលនិងចាត់ចែងការបណ្តុះបណ្តាលទាំងនៅក្នុងនិងក្រៅប្រទេសសម្រាប់មន្ត្រីរាជការព្រមទាំងទស្សនកិច្ចសិក្សា
- រៀបចំ គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំលើព័ត៌មាន ទិន្នន័យ និងស្ថិតិពាក់ព័ន្ធមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា ដោយសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា
- សម្របសម្រួលនិងរៀបចំធ្វើបណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា
- សម្របសម្រួលនិងចាត់ចែងកិច្ចគាំពារសង្គមសម្រាប់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១៣ .-**

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្មមានភារកិច្ច ដូចខាងក្រោម៖

- ទំនាក់ទំនងជាមួយស្ថានទូត ក្រសួងស្ថាប័នពាក់ព័ន្ធលើកិច្ចការអន្តរជាតិ

- ស្រាវជ្រាវ ចងក្រង និងរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលិខិតូបករណ៍គតិយុត្តពាក់ព័ន្ធកិច្ចការព្រំដែន
- រៀបចំប្រែសម្រួលនិងបកប្រែឯកសារបរទេស មានជាអាទិ៍ភាសាបារាំង អង់គ្លេស ថៃ វៀតណាម និងភាសាឡាវ
- ចូលរួមកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន និងវេទិកាជាតិនិងអន្តរជាតិពាក់ព័ន្ធ តាមការចាំបាច់
- សម្របសម្រួលនិងប្រមូលចងក្រងឯកសារបម្រើឱ្យការចរចាពាក់ព័ន្ធនឹងកិច្ចការព្រំដែន ដោយសហការជាមួយអង្គភាពជំនាញ
- ចូលរួមក្នុងគ្រប់ដំណើរការចរចាការងារពាក់ព័ន្ធកិច្ចការព្រំដែន
- ចូលរួមរៀបចំជំនួយស្មារតី ចំណុចពិភាក្សាលើកិច្ចការព្រំដែន សម្រាប់កិច្ចប្រជុំថ្នាក់ដឹកនាំ ទស្សនកិច្ចនៅបរទេស និងទឡ្ហីករណ៍តវ៉ាអំពីការរំលោភបូរណភាពទឹកដីអធិបតេយ្យភាពកម្ពុជាតាមផ្លូវការទូត សន្និសីទសារព័ត៌មាន សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ និងការងារទំនាក់ទំនងសាធារណៈដទៃទៀត តាមការចាំបាច់
- ចូលរួមនិងសម្របសម្រួលកិច្ចប្រជុំផ្ទៃក្នុង កិច្ចប្រជុំទ្វេភាគី និងកិច្ចប្រជុំពហុភាគី
- សហការជាមួយវិទ្យាស្ថានជាតិកិច្ចការព្រំដែន ក្នុងការរៀបចំកម្មវិធីបាឋកថា វេទិកាពិភាក្សា សិក្ខាសាលាជាតិនិងអន្តរជាតិ និងព្រឹត្តិការណ៍នានាពាក់ព័ន្ធកិច្ចការព្រំដែន
- សហការរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗជូនថ្នាក់ដឹកនាំរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំឯកសារបម្រើឱ្យការងារបេសកកម្មក្រៅប្រទេស មានជាអាទិ៍លិខិតឆ្លងដែន ទិដ្ឋាការ ឯកសារធ្វើដំណើរជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

**មាត្រា១៤ .-**

នាយកដ្ឋានព័ត៌មានវិទ្យាមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពការងារពាក់ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងរដ្ឋបាលឌីជីថល
- ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យឌីជីថល
- វាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- កសាង ដំឡើង អភិវឌ្ឍ ថែទាំ ជួសជុល និងធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបម្រើឱ្យរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយសហការជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ
- សម្របសម្រួលនិងសហការផ្តល់សេវាបច្ចេកវិទ្យាព័ត៌មានដល់អង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បណ្តុះបណ្តាល ពង្រឹង និងធ្វើបច្ចុប្បន្នភាពសមត្ថភាពរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលប្រកបដោយសុវត្ថិភាព

- គ្រប់គ្រងសារពើភណ្ឌហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- ចូលរួមវាយតម្លៃលទ្ធកម្មសម្ភារៈបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តការកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន

**មាត្រា១៥ .-**

អគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន ជាសេនាធិការជូនរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ក្នុងការផ្តល់សេវាគាំទ្រលើផ្នែកបច្ចេកទេសវាស់វែង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងការផលិតផែនទីសម្រាប់កិច្ចការព្រំដែនគោកនិងព្រំដែនសមុទ្រ ព្រមទាំងការដោះស្រាយបាតុភាពនានាដែលកើតឡើងនៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាង ហើយមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំនិងដឹកនាំអនុវត្តផែនការមេនិងផែនការសកម្មភាពពាក់ព័ន្ធ ជាអាទិ៍ការវាស់វែង ការខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក ការកំណត់ព្រំដែនសមុទ្រ ការឃ្លាំមើលនិងការចុះត្រួតពិនិត្យស្ថានភាពតាមព្រំដែន ការចុះស្រង់និងប្រមូលទិន្នន័យព័ត៌មានភូមិសាស្ត្រលើទីតាំងជាក់ស្តែង ទាំងនៅលើដីគោក លើផ្ទៃនិងបាតសមុទ្រ ព្រមទាំងតាមបណ្តាកោះនានា
- ចូលរួមក្នុងកិច្ចប្រជុំនិងកិច្ចចរចាទ្វេភាគីនិងពហុភាគីលើកិច្ចការព្រំដែន
- ទទួលខុសត្រូវដឹកនាំរៀបចំកំណត់ហេតុនិងរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំនានា ពាក់ព័ន្ធកិច្ចការបច្ចេកទេសវាស់វែងព្រំដែន
- ដឹកនាំការអនុវត្តការងារវាស់វែង ខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រ
- ដឹកនាំការផលិតផែនទីព្រំដែន បង្គោលព្រំដែន និងសញ្ញាសម្គាល់ព្រំដែនគោកនិងព្រំដែនសមុទ្រជាមួយប្រទេសជិតខាង
- ដឹកនាំការងារថែទាំ ជួសជុល និងកែលម្អបង្គោលព្រំដែននិងសញ្ញាសម្គាល់ព្រំដែន
- ដឹកនាំ រៀបចំបង្កើតបទដ្ឋានបច្ចេកទេស សម្រាប់ការផលិតផែនទីព្រំដែនគោក ផែនទីព្រំដែនសមុទ្រ និងសំណង់បង្គោលព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សានិងចុះស្រាវជ្រាវខ្សែព្រំដែន បង្គោលព្រំដែនចាស់ ឋានលេខាភូមិសាស្ត្រ វត្ថុជាតុគោលទុកជាមូលដ្ឋានសម្រាប់ការចរចាលើការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រជាមួយប្រទេសជិតខាង និងជាទិន្នន័យសម្រាប់ការចូលរួមធ្វើផែនការនិងការសម្រេចចិត្តលើការអភិវឌ្ឍតំបន់ព្រំដែន
- បង្កើត ធ្វើបច្ចុប្បន្នកម្មជាប្រចាំ គ្រប់គ្រង និងថែរក្សាមូលដ្ឋានទិន្នន័យភូមិសាស្ត្រដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើវិភាគ និងផលិតផែនទីព្រំដែនគ្រប់ប្រភេទ គ្រប់មាត្រដ្ឋាន ដែលអនុញ្ញាតដោយបច្ចេកវិទ្យានិងវិទ្យាសាស្ត្រថ្មីៗ
- ដឹកនាំរៀបចំកិច្ចការសិក្សាស្រាវជ្រាវអំពីឧបករណ៍និងវិធីសាស្ត្រវាស់វែងថ្មីៗព្រមទាំងកម្មវិធីអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រនិងការផលិតផែនទី

- ចូលរួមរៀបចំព័ត៌មានភូមិសាស្ត្រនិងការបោះពុម្ពផែនទីគ្រប់ប្រភេទ មានជាអាទិ៍ផែនទីធនធានធម្មជាតិ ផែនទីរដ្ឋបាល ផែនទីសេដ្ឋកិច្ច ផែនទីប្រជាសាស្ត្រ ផែនទីអភិវឌ្ឍន៍តាមបណ្តាខេត្តជាប់ព្រំដែន ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធ
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសកិច្ចការព្រំដែនជូនអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន
- ដឹកនាំការងារវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់ដែលកើតចេញពីការកំណត់ព្រំដែនគោក ការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក ការកំណត់ព្រំដែនសមុទ្រ ការបង្កើតនិងការដំឡើងកម្រិតច្រកទ្វារព្រំដែន
- ចូលរួមជាមួយក្រសួង ស្ថាប័នក្នុងការបង្កើតនិងដំឡើងកម្រិតច្រកទ្វារព្រំដែន គម្រោងឬផែនការអភិវឌ្ឍន៍តំបន់ព្រំដែន
- ដឹកនាំគ្រប់គ្រងលើផ្នែកបច្ចេកទេសសំណង់ ការរចនាប្លង់បង្គោលព្រំដែន ប្លង់បរិវេណបង្គោលព្រំដែន ការសាងសង់បង្គោលព្រំដែន និងសំណង់ផ្សេងទៀតពាក់ព័ន្ធព្រំដែន ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ លើការគ្រប់គ្រងលើផ្នែកបច្ចេកទេសសំណង់ ការរចនាប្លង់សំណង់តាមផ្លូវទឹកព្រំដែន
- ដឹកនាំរៀបចំផែនការសកម្មភាពនិងផែនការថវិកាប្រចាំឆ្នាំ ដាក់ជូនអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- តាមដាន ស្រាវជ្រាវ ស៊ើបអង្កេត និងសម្របសម្រួល ដោះស្រាយបាតុភាពតាមបណ្តោយព្រំដែន
- លើកសំណើស្តីពីការដោះស្រាយផលប៉ះពាល់ពីការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនជូនរដ្ឋមន្ត្រីដើម្បីគោរពស្នើសុំការពិនិត្យ សម្រេចពីប្រមុខរាជរដ្ឋាភិបាល
- ដឹកនាំអនុវត្តដំណោះស្រាយផលប៉ះពាល់ពីការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ របស់អគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**មាត្រា១៦ .-**

អគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន មាននាយកដ្ឋានចំណុះចំនួន៣(បី) ដូចខាងក្រោម៖
- នាយកដ្ឋានវាស់វែង
- នាយកដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ផែនទី និងសំណង់
- នាយកដ្ឋានដោះស្រាយបាតុភាពតាមបណ្តោយព្រំដែន។

**មាត្រា១៧ .-**

នាយកដ្ឋានវាស់វែងមានភារកិច្ច ដូចខាងក្រោម៖
- សិក្សាលើកយោបល់ រៀបចំ និងអនុវត្តផែនការមេនិងផែនការសកម្មភាពវាស់វែង ខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រ

- ចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីនិងពហុភាគីជាមួយប្រទេសជិតខាង ក្នុងការខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រ និងចូលរួមធ្វើកំណត់ហេតុកិច្ចប្រជុំ
- ផ្តួចផ្តើមស្រាវជ្រាវ រៀបចំ បង្កើត និងធ្វើបច្ចុប្បន្នភាពបទដ្ឋានបច្ចេកទេស ដើម្បីធានាសុក្រឹតភាពលើលទ្ធផលនៃការងារវាស់វែងគ្រប់ប្រភេទ ដោយសហការជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ
- ទទួលខុសត្រូវវាស់វែង បង្កើតបណ្តាញបង្គោលប្រឹថពីវិភាគគ្រប់ថ្នាក់ វាស់វែងឋានលេខា វាស់វែងជលសាស្ត្រសម្រាប់បម្រើឱ្យការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រ បម្រើឱ្យការអភិវឌ្ឍតំបន់ព្រំដែន និងធ្វើផែនទីតាមតំបន់ព្រំដែន
- ចុះអនុវត្តលើដីជាក់ស្តែងដើម្បីរុករកបង្គោលព្រំដែនចាស់និងកំណត់ទីតាំងបង្គោលព្រំដែនជាថ្មីឡើងវិញ ក្នុងករណីដែលបាត់ឬនៅមិនចំទីតាំងដើម
- សិក្សានិងចុះស្រាវជ្រាវខ្សែព្រំដែន បង្គោលព្រំដែនចាស់ ឋានលេខាភូមិសាស្ត្រ វត្ថុជាតុគោលទុកជាមូលដ្ឋានសម្រាប់ការចរចាលើការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រជាមួយប្រទេសជិតខាង និងជាទិន្នន័យសម្រាប់ការចូលរួមធ្វើផែនការនិងការសម្រេចចិត្តលើការអភិវឌ្ឍតំបន់ព្រំដែន
- ចុះធ្វើការវាស់វែង ខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រជាមួយប្រទេសជិតខាង ព្រមទាំងរៀបចំកំណត់ហេតុនិងរបាយការណ៍
- ទទួលខុសត្រូវត្រួតពិនិត្យនិងផ្ទៀងផ្ទាត់រាល់លទ្ធផលនៃការវាស់វែងបឋមលើដីជាក់ស្តែងនិងលទ្ធផលនៃការបោះបង្គោលដោយក្រុមការងារបច្ចេកទេស
- ចងក្រងឯកសារបច្ចេកទេសនិងលទ្ធផលនៃការវាស់វែង ខណ្ឌសីមានិងបោះបង្គោលព្រំដែន
- សិក្សា ស្រាវជ្រាវ លើកសំណើបញ្ជាទិញ និងចូលរួមធ្វើលទ្ធកម្មទិញបច្ចេកវិទ្យានិងសម្ភារៈបរិក្ខារចាំបាច់សម្រាប់បម្រើឱ្យតួនាទីភារកិច្ចរបស់ខ្លួន ដោយសហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ
- ផ្តល់ការគាំទ្រលើផ្នែកវាស់វែង ជូនអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន
- ផ្តល់ការគាំទ្រដល់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ លើការងារតាក់តែងលិខិតូបករណ៍នានា និងការងារចរចាជាមួយបណ្តាប្រទេសជិតខាង
- សិក្សាលើកយោបល់និងចូលរួមក្នុងការផលិតផែនទីព្រំដែន បង្គោលព្រំដែន និងសញ្ញាសម្គាល់ព្រំដែនគោកនិងព្រំដែនសមុទ្រជាមួយប្រទេសជិតខាង
- សិក្សា ស្រាវជ្រាវអំពីឧបករណ៍និងវិធីសាស្ត្រវាស់វែងគ្រប់ប្រភេទដែលសមស្របសម្រាប់តម្រូវការលើកិច្ចការព្រំដែននាពេលបច្ចុប្បន្ននិងអនាគត
- សហការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធអំពីបច្ចេកទេសនិងវិធីសាស្ត្រវាស់វែងថ្មីៗ
- សិក្សាឯកសារ ទិន្នន័យ ព័ត៌មាន និងរបកគំហើញនានារបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែនដើម្បីប្រើប្រាស់ជាមូលដ្ឋាន បម្រើឱ្យគោលដៅខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រ
- ប្រគល់ជូនឯកសារបច្ចេកទេសច្បាប់ដើមពាក់ព័ន្ធការងារវាស់វែងនិងខណ្ឌសីមាព្រំដែនគោកនិងការកំណត់ព្រំដែនសមុទ្រ ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

- ចូលរួមរៀបចំកម្មវិធីបណ្តុះបណ្តាល ចែករំលែកចំណេះដឹង និងបទពិសោធនានា តាមសំណូមពរវិទ្យាស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- ប្រើប្រាស់និងថែទាំឧបករណ៍ សម្ភារៈ បរិក្ខារគ្រប់ប្រភេទ សម្រាប់បម្រើឱ្យការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងផលិតផែនទី ស្របតាមវិធាន គោលការណ៍ និងសេចក្តីណែនាំនានាដែលចេញដោយអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- រៀបចំ ថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរក្សាទុកទិន្នន័យផ្ទៃក្នុង ដោយសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន។

**មាត្រា១៨ .-**

នាយកដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ផែនទី និងសំណង់មានភារកិច្ច ដូចខាងក្រោម៖
- រៀបចំបង្កើត ធ្វើបច្ចុប្បន្នភាពជាប្រចាំ គ្រប់គ្រង និងថែរក្សាមូលដ្ឋានទិន្នន័យភូមិសាស្ត្រដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើវិភាគនិងផលិតផែនទីព្រំដែនគ្រប់ប្រភេទ
- រៀបចំផែនការមេនិងផែនការសកម្មភាពចុះស្រង់និងប្រមូលទិន្នន័យ ព័ត៌មានភូមិសាស្ត្រលើទីតាំងជាក់ស្តែង ទាំងនៅលើដីគោក សមុទ្រ និងតាមបណ្តាកោះនានា ដើម្បីផលិតផែនទីនិងសាងសង់បង្គោលព្រំដែន
- ចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីនិងពហុភាគីជាមួយប្រទេសជិតខាង ក្នុងការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក រួមទាំងកំណត់ព្រំដែនសមុទ្រ និងចូលរួមធ្វើកំណត់ហេតុកិច្ចប្រជុំការខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រជាមួយប្រទេសជិតខាង
- ទទួលខុសត្រូវផលិតផែនទីពាក់ព័ន្ធព្រំដែន ជាអាទិ៍ផែនទីឋានលេខាខ្សែព្រំដែន ប្លង់ ផែនទីសមុទ្រ និងផែនទីជលសាស្ត្រ
- សិក្សានិងរៀបចំកម្មវិធីអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ឱ្យបានសមស្របទៅតាមតម្រូវការបច្ចុប្បន្ននិងអនាគត
- សិក្សា ស្រាវជ្រាវ ប្រមូល ចងក្រងនាមភូមិសាស្ត្រនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សា តាមដានជាប្រចាំអំពីការបោះពុម្ពនិងផ្សព្វផ្សាយផែនទី ពាក់ព័ន្ធព្រំដែនគ្រប់ប្រភេទនៃព្រះរាជាណាចក្រកម្ពុជានិងប្រទេសជិតខាង
- ចូលរួមជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន ក្នុងការរៀបចំព័ត៌មានភូមិសាស្ត្រនិងការបោះពុម្ពផែនទីគ្រប់ប្រភេទពាក់ព័ន្ធព្រំដែន
- សិក្សា ស្រាវជ្រាវ លើកសំណើបញ្ជាទិញ និងចូលរួមធ្វើលទ្ធកម្មទិញឧបករណ៍ថ្មីៗដែលជាប្រយោជន៍ដល់ការបង្កើនប្រសិទ្ធភាពនិងសុក្រឹតភាពនៃការចាប់យកទិន្នន័យព័ត៌មានភូមិសាស្ត្រនិងការផលិតផែនទី

- សហការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ អំពីបច្ចេកទេសកសាងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងការផលិតផែនទីពាក់ព័ន្ធព្រំដែន
- ប្រគល់ជូនឯកសារច្បាប់ដើមពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងការផលិតផែនទីជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន ដើម្បីតម្កល់ទុក
- សិក្សាឯកសារ ទិន្នន័យ ព័ត៌មាន និងរបកគំហើញនានារបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន ដើម្បីប្រើប្រាស់ជាមូលដ្ឋាន បម្រើឱ្យគោលដៅខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក កំណត់ព្រំដែនសមុទ្រ និងការផលិតផែនទីព្រំដែន
- ចូលរួមក្នុងការសិក្សានិងវិភាគព័ត៌មាននិងទិន្នន័យចាំបាច់ជាមូលដ្ឋាននៃការខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក និងកំណត់ព្រំដែនសមុទ្រ
- ដឹកនាំគ្រប់គ្រងលើផ្នែកបច្ចេកទេសសំណង់ ការរចនាប្លង់បង្គោលព្រំដែន ប្លង់បរិវេណបង្គោលព្រំដែន សំណង់តាមផ្លូវទឹកព្រំដែន ព្រមទាំងការសាងសង់បង្គោលព្រំដែននិងសំណង់ផ្សេងៗទៀតពាក់ព័ន្ធព្រំដែន
- ចុះត្រួតពិនិត្យ ថែទាំ និងជួសជុលបង្គោលព្រំដែននិងសញ្ញាសម្គាល់ព្រំដែន
- គ្រប់គ្រងរោងពុម្ពផលិតផែនទីនិងបោះពុម្ពផែនទីព្រំដែនគ្រប់ប្រភេទ
- ធ្វើបច្ចុប្បន្នភាពលើផែនទីខ្សែព្រំដែននិងផែនទីតំបន់ព្រំដែន
- ផ្តល់ការគាំទ្រលើវិស័យប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ជូនអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន
- ពិនិត្យ ផ្ទៀងផ្ទាត់ និងលើកយោបល់លើការបោះពុម្ពនិងការផ្សព្វផ្សាយផែនទីពាក់ព័ន្ធព្រំដែនគ្រប់ទម្រង់ គ្រប់ប្រភេទ និងគ្រប់មាត្រដ្ឋាន ជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន សំដៅធានាបាននូវឯកភាពលើផ្ទៃប្រទេស
- ចូលរួមរៀបចំកម្មវិធីបណ្តុះបណ្តាល ចែករំលែកចំណេះដឹង និងបទពិសោធនានា តាមសំណូមពររបស់វិទ្យាស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តជាប់ព្រំដែន
- រៀបចំ ថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរក្សាទុកទិន្នន័យផ្ទៃក្នុង ដោយសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន។

**មាត្រា១៩ .-**

នាយកដ្ឋានដោះស្រាយបាតុភាពតាមបណ្តោយព្រំដែនមានភារកិច្ច ដូចខាងក្រោម៖

- តាមដាន ស្រាវជ្រាវ ស៊ើបអង្កេត និងសម្របសម្រួលដោះស្រាយបាតុភាពតាមបណ្តោយព្រំដែន
- លើកសំណើស្តីពីការដោះស្រាយផលប៉ះពាល់ពីការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនជូនអគ្គនាយកពិនិត្យនិងចាត់នីតិវិធីបន្ត
- ចុះអនុវត្តដំណោះស្រាយផលប៉ះពាល់ពីការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន អនុលោមតាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល

- រៀបចំផែនការមេនិងផែនការសកម្មភាពពាក់ព័ន្ធការឃ្លាំមើល និងត្រួតពិនិត្យស្ថានភាពតាមព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន
- ចុះឃ្លាំមើលនិងចុះត្រួតពិនិត្យស្ថានភាពតាមព្រំដែនតាមផែនការ ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន
- ចុះស៊ើបអង្កេត ប្រមូលព័ត៌មាននិងទិន្នន័យនៅទីតាំងជាក់ស្តែង ពាក់ព័ន្ធបាតុភាពតាមព្រំដែនដែលកើតមានជាយថាហេតុ ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន និងរាយការណ៍លើកយោបល់ជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- ចុះពិនិត្យនិងវាយតម្លៃផលប៉ះពាល់ដែលអាចបង្កឡើងដោយសកម្មភាពមនុស្សឬធម្មជាតិចំពោះខ្សែបន្ទាត់ព្រំដែន បង្គោលព្រំដែន និងសញ្ញាសម្គាល់ព្រំដែនក្នុងតំបន់ឯកភាព និងចំពោះការងារខណ្ឌសីមានិងបោះបង្គោលព្រំដែនក្នុងតំបន់មិនទាន់ឯកភាព ព្រមទាំងការកំណត់ព្រំដែនសមុទ្រ
- វាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់ដែលកើតចេញពីការខណ្ឌសីមា ការបោះបង្គោលព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រ ដាក់ជូនរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនដោះស្រាយ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែន
- ចុះស៊ើបអង្កេត ប្រមូលព័ត៌មាននិងទិន្នន័យនៅលើដីជាក់ស្តែងពាក់ព័ន្ធបាតុភាពតាមបណ្តោយព្រំដែន ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីទទួលបាននូវការគាំទ្រ ដែលចាំបាច់ជាអាទិ៍ឧបករណ៍វាស់វែងនិងទិន្នន័យមន្ត្រីនិងបុគ្គលិក
- ចូលរួមចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ព្រំដែន ខណ្ឌសីមា និងបោះបង្គោលព្រំដែន
- ប្រគល់ឯកសារពាក់ព័ន្ធការងារដោះស្រាយបាតុភាពតាមព្រំដែនគោកនិងព្រំដែនសមុទ្រ ជូនមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- ចូលរួមឬសិក្សាអំពីហេតុប៉ះពាល់និងផលប៉ះពាល់ដែលអាចកើតមានពីការបង្កើត ការដំឡើងកម្រិតច្រកទ្វារព្រំដែន គម្រោងឬផែនការអភិវឌ្ឍន៍តំបន់ព្រំដែន និងរាយការណ៍លើកយោបល់ជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំ ថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរក្សាទុកទិន្នន័យផ្ទៃក្នុងដោយសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន។

## ជំពូកទី៦

## អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន

**មាត្រា២០ .-**

អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន ជាសេនាធិការរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនលើការងារសម្របសម្រួល ដឹកនាំរៀបចំគោលនយោបាយអភិវឌ្ឍន៍តំបន់ព្រំដែន ដឹកនាំ

ការអភិវឌ្ឍនិងផ្តល់ការគាំពារដល់ការអភិវឌ្ឍខេត្តជាប់ព្រំដែន ដើម្បីជាប្រយោជន៍ដល់កិច្ចការពារព្រំដែន ហើយមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំរៀបចំនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ ផែនការជាតិអភិវឌ្ឍន៍តំបន់ព្រំដែនផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍតំបន់ព្រំដែន និងលើកទឹកចិត្តដល់ការកសាងសហគមន៍ និងបង្កើតសកម្មភាពអភិវឌ្ឍតំបន់ព្រំដែន
- បញ្ជ្រាបគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែន ទៅក្នុងផែនការអភិវឌ្ឍន៍ និងវិនិយោគរបស់រដ្ឋបាលខេត្តជាប់ព្រំដែន
- ពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីកៀរគរធនធាននិងជំនួយបច្ចេកទេស ព្រមទាំងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់ព្រំដែន
- ដឹកនាំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន
- ដឹកនាំការងារវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នានានៅតំបន់ព្រំដែន ដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធនឹងវិស័យឯកជន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- លើកសំណើដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នៅតំបន់ព្រំដែនជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ពិនិត្យនិងសម្រេច
- ដឹកនាំដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រនៅតំបន់ព្រំដែនដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចូលរួមត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចក្នុងក្របខ័ណ្ឌបច្ចេកទេសព្រំដែនលើគម្រោងវិនិយោគនិងគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន
- ដឹកនាំកំណត់តំបន់ទ្រនាប់ខ្សែបន្ទាត់ព្រំដែន ពិនិត្យគម្រោងវិនិយោគតាមព្រំដែនដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធ
- ដឹកនាំរៀបចំផែនការសកម្មភាពនិងផែនការថវិកាប្រចាំឆ្នាំ ដាក់ជូនអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ដឹកនាំរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ ផែនការជាតិអភិវឌ្ឍន៍តំបន់ព្រំដែន ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍតំបន់ព្រំដែន ជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ពិនិត្យនិងសម្រេច
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**មាត្រា២១ .-**

អគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន មាននាយកដ្ឋានចំណុះចំនួន៣(បី) ដូចខាងក្រោម៖

- នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
- នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែន
- នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែន។

**មាត្រា២២ .-**

នាយកដ្ឋានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំនិងអភិវឌ្ឍចក្ខុវិស័យ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ទ្រទ្រង់និងលើកទឹកចិត្តដល់ការអភិវឌ្ឍតំបន់ព្រំដែន ដើម្បីស្រូបទាញការតាំងទីលំនៅ ការកសាងសហគមន៍ និងការប្រកបសកម្មភាពសេដ្ឋកិច្ចដ៏រស់រវើក មានជាអាទិ៍ការដោះដូរ ពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ជាប្រយោជន៍ដល់ការការពារបូរណភាពទឹកដី
- សិក្សា ស្រាវជ្រាវ ចងក្រងអំពីឧត្តមានុវត្តអន្តរជាតិពាក់ព័ន្ធការងារអភិវឌ្ឍតំបន់ព្រំដែន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសម្រាប់ ការអភិវឌ្ឍតំបន់ព្រំដែនប្រកបដោយចីរភាព និងលើកយោបល់កែលម្អ
- ចូលរួមផ្សព្វផ្សាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងការអភិវឌ្ឍតំបន់ព្រំដែន ដោយសហការជាមួយវិទ្យាស្ថានជាតិកិច្ចការព្រំដែន
- ចូលរួមផ្តល់យោបល់លើផែនការអភិវឌ្ឍន៍និងវិនិយោគរបស់ខេត្តជាប់ព្រំដែន ដើម្បីជាប្រយោជន៍ ដល់ការធ្វើសមាហរណកម្ម និងការលើកកម្ពស់ដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសម្រាប់ការអភិវឌ្ឍតំបន់ព្រំដែនប្រកបដោយចីរភាព ដោយសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំផែនការមេនិងផែនការតាមវិស័យ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធតាមការ ចាំបាច់
- តាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងការ អភិវឌ្ឍតំបន់ព្រំដែនប្រកបដោយចីរភាព
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងអភិវឌ្ឍន៍តំបន់ព្រំដែន។

**មាត្រា២៣ .-**

នាយកដ្ឋានអភិវឌ្ឍន៍ព្រំដែនមានភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែន
- សិក្សា ស្រាវជ្រាវ ចងក្រងអំពីឧត្តមានុវត្តអន្តរជាតិទាក់ទងនឹងបច្ចេកទេសនិងហិរញ្ញប្បទាន ពាក់ព័ន្ធការងារអភិវឌ្ឍតំបន់ព្រំដែន

- ពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីកៀរគរធនធាននិងជំនួយបច្ចេកទេស ព្រមទាំងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់ព្រំដែន
- សិក្សា វាយតម្លៃ សមិទ្ធិលទ្ធភាព និងស្នើគម្រោងអភិវឌ្ឍន៍ ជាអាទិ៍គម្រោងហេដ្ឋារចនាសម្ព័ន្ធព្រំដែនដែលមានលក្ខណៈយុទ្ធសាស្ត្រ ជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ពិនិត្យនិងសម្រេច
- ដឹកនាំរៀបចំការងារវាយតម្លៃហេតុប៉ះពាល់និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រនៅតំបន់ព្រំដែន ដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធ និងវិស័យឯកជន អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- លើកសំណើដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នៅតំបន់ព្រំដែនជូនអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន ពិនិត្យនិងចាត់នីតិវិធីបន្ត
- ដឹកនាំដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រនៅតំបន់ព្រំដែន ដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចូលរួមត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចក្នុងក្របខ័ណ្ឌបច្ចេកទេសព្រំដែនលើគម្រោងវិនិយោគនិងគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន
- ចុះកំណត់តំបន់ទ្រនាប់ខ្សែបន្ទាត់ព្រំដែន ពិនិត្យគម្រោងវិនិយោគតាមព្រំដែនដោយសហការជាមួយអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការជាតិនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍតាមតំបន់ព្រំដែន ព្រមទាំងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តការកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន។

**មាត្រា២៤ .-**

នាយកដ្ឋានត្រួតពិនិត្យនិងគាំពារការអភិវឌ្ឍខេត្តជាប់ព្រំដែនមានភារកិច្ច ដូចខាងក្រោម៖

- ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានា ជាអាទិ៍ប្រមូលចងក្រងសំណូមពរ បញ្ហាប្រឈម ផលប៉ះពាល់ និងតម្រូវការរបស់ដៃគូអភិវឌ្ឍប្រជាពលរដ្ឋ សហគមន៍ និងអាជ្ញាធរមូលដ្ឋាន
- បញ្ជ្រាបគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន ទៅក្នុងផែនការអភិវឌ្ឍនិងវិនិយោគរបស់រដ្ឋបាលខេត្តជាប់ព្រំដែន
- សហការជាមួយបណ្តាក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តជាប់ព្រំដែនពាក់ព័ន្ធ ក្នុងការសិក្សាវាយតម្លៃអំពីតម្រូវការ និងតម្រង់ទិសនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាង

- សហការត្រួតពិនិត្យរាល់ការសាងសង់សំណង់និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានានៅតាមបណ្ដោយខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាង ដើម្បីបង្ការផលប៉ះពាល់ដល់ការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍតាមតំបន់ព្រំដែន ព្រមទាំងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងអភិវឌ្ឍន៍តំបន់ព្រំដែន។

## ជំពូកទី៧
## វិទ្យាស្ថានជាតិកិច្ចការព្រំដែន

**មាត្រា២៥ .-**

វិទ្យាស្ថានជាតិកិច្ចការព្រំដែន ជាសេនាធិការរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែនលើការងារបណ្ដុះបណ្ដាលច្បាប់ជាតិ ច្បាប់អន្តរជាតិ និងបច្ចេកទេសកិច្ចការព្រំដែន សិក្សាស្រាវជ្រាវនិងវិភាគជាយុទ្ធសាស្ត្រកិច្ចការព្រំដែន រក្សានិងគ្រប់គ្រងឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងកិច្ចការព្រំដែន ហើយមានភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ ដឹកនាំរៀបចំ និងអភិវឌ្ឍគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីស្រាវជ្រាវ បណ្ដុះបណ្ដាលច្បាប់ បច្ចេកទេសព្រំដែននិងផ្សព្វផ្សាយច្បាប់
- ដឹកនាំសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សាយច្បាប់ជាតិ ច្បាប់អន្តរជាតិ និងមុខវិជ្ជាជំនាញពាក់ព័ន្ធផ្សេងទៀត
- ដឹកនាំស្រាវជ្រាវវិភាគជាយុទ្ធសាស្ត្រ តាមដាន និងវាយតម្លៃសភាពការណ៍ និងព័ត៌មានពាក់ព័ន្ធកិច្ចការព្រំដែន ព្រមទាំងលើកយោបល់ជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- កសាងនិងអភិវឌ្ឍសមត្ថភាពវិទ្យាស្ថានជាតិកិច្ចការព្រំដែន និងធ្វើទំនើបកម្មកម្មវិធីបណ្ដុះបណ្ដាល
- ដឹកនាំ សម្របសម្រួល ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាតាមភូមិសិក្សាពាក់ព័ន្ធភូមិវិទ្យានិងផែនទីដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- កសាង ពង្រឹង និងពង្រីកភាពជាដៃគូជាមួយនឹងវិស័យឯកជន វិទ្យាស្ថាន សាកលវិទ្យាល័យ និងគ្រឹះស្ថានស្រាវជ្រាវជាតិនិងអន្តរជាតិ
- ដឹកនាំសម្របសម្រួល រៀបចំ កម្មវិធីបណ្ដុះបណ្ដាលជូនមន្ត្រីរាជការបម្រើការនៅរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងខេត្តជាប់ព្រំដែន ព្រមទាំងរៀបចំទស្សនកិច្ចសិក្សាជូនប្រជាពលរដ្ឋ សិស្ស និស្សិត និងមន្ត្រីរាជការតាមបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដឹកនាំបង្កើត គ្រប់គ្រង និងធ្វើទំនើបកម្មបណ្ណាល័យ បណ្ណាល័យអេឡិចត្រូនិក ឯកសារវីដេអូបណ្ណាល័យសោតទស្សន៍ និងប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់បម្រើឱ្យគោលដៅស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់ជាតិនិងច្បាប់អន្តរជាតិ

- លើកស្ទួយការបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវផ្សេងៗ
- ដឹកនាំរៀបចំផែនការសកម្មភាពនិងផែនការថវិកាប្រចាំឆ្នាំដាក់ជូនអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**មាត្រា២៦ .-**

វិទ្យាស្ថានជាតិកិច្ចការព្រំដែនមាននាយកដ្ឋានចំណុះចំនួន៣(បី) ដូចខាងក្រោម៖
- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានស្រាវជ្រាវនិងវិភាគជាយុទ្ធសាស្ត្រ
- នាយកដ្ឋានបណ្តុះបណ្តាលនិងផ្សព្វផ្សាយ។

**មាត្រា២៧ .-**

នាយកដ្ឋានកិច្ចការទូទៅមានភារកិច្ច ដូចខាងក្រោម៖
- ទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យារបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- រៀបចំផែនការសកម្មភាពការងារនិងផែនការថវិកា សម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- សហការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព ដើម្បីពង្រឹងគុណភាពនៃការបណ្តុះបណ្តាល
- រៀបចំកិច្ចប្រជុំនិងពិធីផ្សេងៗរបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- សម្របសម្រួលការគ្រប់គ្រងអគារ សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងវិទ្យាស្ថានជាតិកិច្ចការព្រំដែន
- សម្របសម្រួលការបណ្តុះបណ្តាលមន្ត្រីដែលត្រូវបានជ្រើសរើសថ្មីនិងមន្ត្រីកំពុងបម្រើការងារនៅរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំដំណើរការកម្មវិធីសិក្សានិងការបណ្តុះបណ្តាល
- សម្របសម្រួលជាមួយសាស្ត្រាចារ្យ គ្រូឧទ្ទេស សិក្ខាកាម និងអ្នកសិក្សា ពាក់ព័ន្ធម៉ោងបង្រៀន ឯកសារគរុកោសល្យ និងឯកសារវាយតម្លៃ
- សម្របសម្រួលរៀបចំនិងគ្រប់គ្រងទិន្នន័យ និងឯកសារសិក្ខាកាម អ្នកសិក្សា និងគ្រប់គ្រងដំណើរការបណ្តុះបណ្តាល
- រៀបចំដំណើរការការបណ្តុះបណ្តាលសម្រាប់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលាថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការ និងគម្រោងនានា ព្រមទាំងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន និងវិទ្យាស្ថានជាតិកិច្ចការព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីនាយកវិទ្យាស្ថានជាតិកិច្ចការព្រំដែន។

**មាត្រា២៨ ._**

នាយកដ្ឋានស្រាវជ្រាវនិងវិភាគជាយុទ្ធសាស្ត្រមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយរបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- សិក្សាស្រាវជ្រាវច្បាប់ជាតិ ច្បាប់អន្តរជាតិ លិខិតូបករណ៍គតិយុត្ត គោលការណ៍និងយុត្តិសាស្ត្រអន្តរជាតិ ទ្រឹស្តីច្បាប់ និងបច្ចេកទេសពាក់ព័ន្ធកិច្ចការព្រំដែន ដើម្បីបោះពុម្ពផ្សាយនិងបណ្តុះបណ្តាល
- តាមដាន ស្រាវជ្រាវ សិក្សា និងវិភាគអំពីសភាពការណ៍និងព័ត៌មានពាក់ព័ន្ធកិច្ចការព្រំដែន ដោយសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ
- កៀរគរធនធាននិងដៃគូ គាំពារ និងលើកទឹកចិត្តការសិក្សាស្រាវជ្រាវនិងបោះពុម្ពផ្សាយឯកសារនានាពាក់ព័ន្ធកិច្ចការព្រំដែន
- កសាង ពង្រឹង និងពង្រីកភាពជាដៃគូជាមួយនឹងវិស័យឯកជន វិទ្យាស្ថាន សាកលវិទ្យាល័យ និងគ្រឹះស្ថានស្រាវជ្រាវជាតិនិងអន្តរជាតិ
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការ និងគម្រោងនានា ព្រមទាំងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីនាយកវិទ្យាស្ថានជាតិកិច្ចការព្រំដែន។

**មាត្រា២៩ ._**

នាយកដ្ឋានបណ្តុះបណ្តាលនិងផ្សព្វផ្សាយមានភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការជូនវិទ្យាស្ថានជាតិកិច្ចការព្រំដែន ក្នុងការរៀបចំផែនការ កសាងនិងអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស សមត្ថភាពវិទ្យាស្ថាន និងកម្មវិធីបណ្តុះបណ្តាលច្បាប់ និងបច្ចេកទេសពាក់ព័ន្ធកិច្ចការព្រំដែន
- រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពបណ្តុះបណ្តាល ផ្សព្វផ្សាយ កសាងនិងអភិវឌ្ឍបណ្ណាល័យ
- សិក្សាស្រាវជ្រាវច្បាប់ជាតិ ច្បាប់អន្តរជាតិ លិខិតូបករណ៍គតិយុត្ត គោលការណ៍និងយុត្តិសាស្ត្រអន្តរជាតិ និងមុខវិជ្ជាជំនាញពាក់ព័ន្ធផ្សេងទៀត ដើម្បីបម្រើឱ្យកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពគរុកោសល្យ ដោយសហការជាមួយនាយកដ្ឋានស្រាវជ្រាវនិងវិភាគជាយុទ្ធសាស្ត្រ
- ប្រមូលចងក្រង តម្កល់ទុក និងថែទាំផែនទី លិខិតបទដ្ឋានគតិយុត្ត សៀវភៅនិងឯកសារនានា ដែលទាក់ទងនឹងកិច្ចការព្រំដែនពីអង្គភាពចំណុះឱ្យរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- រៀបចំបង្កើត គ្រប់គ្រង និងធ្វើទំនើបកម្មបណ្ណាល័យ បណ្ណាល័យអេឡិចត្រូនិក និងប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់បម្រើឱ្យគោលដៅស្រាវជ្រាវច្បាប់ជាតិ ច្បាប់អន្តរជាតិ និងការអភិវឌ្ឍ
- រៀបចំនិងដឹកនាំអនុវត្តវិធាន បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងបណ្ណាល័យ និងយន្តការគាំទ្រការអនុវត្តផ្សេងទៀតសម្រាប់លើកស្ទួយគុណភាពនិងកិត្យានុភាពរបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- សម្របសម្រួលដឹកនាំការបោះពុម្ពផ្សាយ ជាអាទិ៍សៀវភៅ ស្នាដៃ ទស្សនាវដ្តី ព្រឹត្តិបត្រ និងឯកសារស្រាវជ្រាវផ្សេង ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធបច្ចេកទេសកិច្ចការព្រំដែន និងដៃគូសហការ
- សិក្សា វាយតម្លៃប្រសិទ្ធភាពការងារសំដៅកំណត់ឱ្យបានពីតម្រូវការសមត្ថភាពជំនាញសម្រាប់លើកស្ទួយសមត្ថភាពរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលនិងគ្រូជំនួយ គ្រូឧទ្ទេស សាស្ត្រាចារ្យ ព្រមទាំងមន្ត្រីច្បាប់ និងមន្ត្រីបច្ចេកទេសនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- រៀបចំវគ្គបណ្តុះបណ្តាលសុក្រឹតការនិងវិក្រឹតការជូនមន្ត្រីរាជការបម្រើការនៅក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងខេត្តជាប់ព្រំដែន
- រៀបចំ សម្របសម្រួលការផ្ទេរ និងចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តពីទីប្រឹក្សានិងអ្នកជំនាញការជាតិនិងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោលនិងគ្រូជំនួយ គ្រូឧទ្ទេស និងសាស្ត្រាចារ្យ
- ធ្វើទំនើបកម្មជាប្រចាំនូវកម្មវិធីបណ្តុះបណ្តាល បច្ចេកទេសគរុកោសល្យ និងសម្ភារៈបរិក្ខារឧបទេសរបស់វិទ្យាស្ថានជាតិកិច្ចការព្រំដែន
- រៀបចំនិងជំរុញការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាតាមភូមិសិក្សាពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីព្រំដែន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- កសាងនិងដឹកនាំការអនុវត្តកម្មវិធីទស្សនកិច្ចសិក្សាតាមបណ្តោយព្រំដែនជូនដល់មន្ត្រីរាជការបម្រើការនៅរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងខេត្តជាប់ព្រំដែន ប្រជាពលរដ្ឋ សិស្ស និស្សិត ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន និងអាជ្ញាធរពាក់ព័ន្ធ
- កសាង ពង្រឹង និងពង្រីកភាពជាដៃគូជាមួយនឹងវិទ្យាស្ថាន សាកលវិទ្យាល័យ គ្រឹះស្ថានស្រាវជ្រាវថ្នាក់ជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍដើម្បីទទួលបានចំណេះជំនាញថ្មីៗ និងការលើកស្ទួយគុណភាពនៃការបណ្តុះបណ្តាលលើកិច្ចការព្រំដែននិងអភិវឌ្ឍន៍
- រៀបចំសម្របសម្រួលទស្សនកិច្ចសិក្សា កម្មសិក្សា និងវគ្គបណ្តុះបណ្តាលក្នុងប្រទេសនិងក្រៅប្រទេសជូនដល់មន្ត្រីរាជការ គ្រូបង្គោលនិងគ្រូជំនួយ គ្រូឧទ្ទេស និងសាស្ត្រាចារ្យនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- កៀរគរធនធានសម្រាប់ទ្រទ្រង់និងលើកស្ទួយការបោះពុម្ពផ្សព្វផ្សាយ ជាអាទិ៍សៀវភៅ ស្នាដៃ ទស្សនាវដ្តី ព្រឹត្តិបត្រ និងឯកសារស្រាវជ្រាវផ្សេងៗ

- រៀបចំឯកសារវីដេអូនិងបណ្ណាល័យសោតទស្សន៍ ព្រមទាំងចូលរួមវេទិកាមហាជននានា ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយនិងអំណាន
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការ និងគម្រោងនានា ព្រមទាំងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីនាយកវិទ្យាស្ថានជាតិកិច្ចការព្រំដែន។

## ជំពូកទី៨
## មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

**មាត្រា៣០ .-**

មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែនមានភារកិច្ច ដូចខាងក្រោម៖
- គ្រប់គ្រងនិងធ្វើទំនើបកម្មមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- ប្រមូល ចងក្រង គ្រប់គ្រង តម្កល់ទុក និងថែទាំឯកសារ ផែនទី និងទិន្នន័យព្រំដែនតាមលក្ខណៈបច្ចេកទេស ដោយធានាឱ្យបាននូវគុណភាពល្អយូរអង្វែង
- រៀបចំវិធានផ្ទៃក្នុងសម្រាប់គ្រប់គ្រងនិងធ្វើចំណាត់ថ្នាក់ឯកសារនិងផែនទី
- គ្រប់គ្រងការចូលប្រើប្រាស់ឯកសារ ផែនទី និងទិន្នន័យស្របតាមវិធានផ្ទៃក្នុងស្តីពីការគ្រប់គ្រងនិងធ្វើចំណាត់ថ្នាក់ឯកសារនិងផែនទី
- ទទួលខុសត្រូវលើការរៀបចំយន្តការអនុវត្តការងារ ដើម្បីធានាភាពសម្ងាត់នៃឯកសារនិងផែនទី
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## ជំពូកទី៩
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៣១ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនិងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១០
## ប្រភពធនធាន

**មាត្រា៣២ .-**

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន មានធនធានសម្រាប់អនុវត្តសកម្មភាពការងារដោយថវិកាជាតិ នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាននូវប្រភពធនធានស្របច្បាប់ដែលរាជរដ្ឋាភិបាលអនុញ្ញាត។

## ជំពូកទី១១
## ថវិកានិងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា៣៣ .-**

ការរៀបចំនិងការអនុវត្តថវិការបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវអនុវត្តផ្អែកលើទំហំឥណទាន និងមុខសញ្ញាថវិកា ដែលត្រូវបានអនុម័តក្នុងច្បាប់ថវិកាប្រចាំឆ្នាំសម្រាប់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិនិងហិរញ្ញវត្ថុរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

**មាត្រា៣៤ .-**

រាល់ឯកសារ ព័ត៌មាន និងទិន្នន័យដែលត្រូវបានរៀបចំ ប្រើប្រាស់ និងបម្រុងប្រើប្រាស់សម្រាប់ការអនុវត្តមុខងារនិងភារកិច្ចរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។ ថ្នាក់ដឹកនាំនិងមន្ត្រីនៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវចាត់ចែងគ្រប់គ្រង និងរក្សាទុករាល់ឯកសារ ព័ត៌មាននិងទិន្នន័យសម្ងាត់របស់ជាតិ នៅក្នុងអង្គភាព ដោយមិនអាចយកចេញ មិនត្រូវធ្វើឱ្យខូចខាត ឬធ្វើឱ្យបាត់បង់ ឬធ្វើឱ្យបែកធ្លាយទៅខាងក្រៅ ដោយប្រការណាមួយឡើយ និងត្រូវប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារនិងភារកិច្ចដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា៣៥ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងការតែងតាំងមន្ត្រីរាជការនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវបន្តមានសុពលភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មន្ត្រីរាជការស៊ីវិលនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលត្រូវបានប៉ះពាល់ដោយការរៀបចំនិងកែសម្រួលរចនាសម្ព័ន្ធថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវរក្សាទុកអត្ថប្រយោជន៍ផ្នែកបៀវត្សយ៉ាងហោចក្នុងកម្រិតដដែល។

# ជំពូកទី១៣
# អវសានប្បញ្ញត្តិ

**មាត្រា៣៦ .-**

អនុក្រឹត្យលេខ១៨២អនក្រ.បក ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១២រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៤
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន**

